

# បច្ចុប្បន្នភាពទីផ្សារ និង ការតាមដានរដូវកាល

ខែធ្នូ ឆ្នាំ២០២២

## ប្រទេសកម្ពុជា

### ផ្តោតលើ៖ ឥទ្ធិពលនៃវិបត្តិស្បៀងអាហារ និងប្រេងឥន្ធនៈសកលលោក លើ តម្លៃស្បៀងអាហារ និងដំណើរការរបស់ផ្សារ

កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ សហការជាមួយ ការិយាល័យទីផ្សារកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**ការិយាល័យទីផ្សារកសិកម្ម**
នាយកដ្ឋានផែនការនឹងស្ថិតិ,
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មៀច យ៉ាឌី meachyady@gmail.com
គេហទំព័រ: https://amis.maff.gov.kh/

**កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ**
ផ្នែកវិភាគ និងធ្វើផែនទីភាពងាយរងគ្រោះនៅក្នុងការិយាល័យប្រចាំប្រទេសកម្ពុជា
Benjamin Scholz benjamin.scholz@wfp.org, ឡុង យ៉ាវ yav.long@wfp.org , ជឿ ច័ន្ទវិបុល chanvibol.choeur@wfp.org, ហួយ វណ្ណារ៉េត vannareth.huoy@wfp.org
គេហទំព័រ៖ https://www.wfp.org/countries/cambodia

# បុព្វកថា

**ជិតរយៈពេល១១ខែនៃជម្លោះអ៊ុយក្រែន** សង្គ្រាមនិងការដាក់ទណ្ឌកម្មលើរុស្ស៊ីកំពុងធ្វើឲ្យប៉ះពាល់ខ្លាំងដល់ទីផ្សារថាមពល និងស្បៀងអាហារ ដោយសារប្រទេសទាំងពីរជាអ្នកនាំចេញគ្រាប់ធញ្ញជាតិសំខាន់ (ជាពិសេសស្រូវសាឡី និងស្រូវបាឡេ) ជីកសិកម្ម (ដូចជាប៉ូតាស្យូម អាសូត ផូស្វ័រ)។ រុស្ស៊ី គឺជាប្រទេសដែលផលិត និងនាំចេញប្រេងឆៅ និងឧស្ម័នធម្មជាតិដ៏ធំរបស់ពិភពលោក។

**សន្ទស្សន៍តម្លៃស្បៀងអាហារសកលរបស់ FAO ក្នុងខែធ្នូថយចុះបន្តិច ធៀបនឹងខែវិច្ឆិកា (-១,៩%)** ដោយសារតែធ្លាក់ចុះតម្លៃប្រេងឆា ធញ្ញជាតិ និងសាច់។ ខណៈពេលដែលសន្ទស្សន៍តម្លៃស្បៀងអាហាររបស់ FAO នៅក្នុងខែធ្នូទាបជាងឆ្នាំមុនបន្តិច ប៉ុន្តែតម្លៃជាមធ្យមរបស់វានៅឆ្នាំ២០២២ គឺខ្ពស់ជាង ១៤,៣% ក្នុងកំឡុងឆ្នាំ២០២១។

**វិបត្តិសេដ្ឋកិច្ចសកល** ដែលត្រូវបានព្យាករណ៍កំណើនប្រហែល២,៧% ក្នុងឆ្នាំ២០២៣ នឹងអាចធ្វើឲ្យតម្លៃស្បៀងអាហារ តម្លៃថាមពល និងតម្លៃលោហៈមានតម្លៃ ធ្លាក់ចុះក្នុងឆ្នាំ ២០២៣ និង២០២៤ ប៉ុន្តែនៅតែខ្ពស់ជាងប្រវត្តិតម្លៃក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ។

**លទ្ធភាពទទួលបានជីកសិកម្ម នឹងក្លាយជាបញ្ហាប្រឈមចម្បងនៅប៉ុន្មានខែខាងមុខ** ដោយសារជីកសិកម្មលើសកលលោកនៅតែមានតម្លៃខ្ពស់ក្នុងឆ្នាំ២០២២។ នេះទំនងជាមានឥទ្ធិពលខ្លាំងដល់ផលិតកម្មស្បៀងអាហារនៅជុំវិញពិភពលោកក្នុងឆ្នាំ២០២៣។ ផលិកម្មស្រូវលើសកលលោកក្នុង ឆ្នាំ ២០២២/២០២៣ ត្រូវបានរំពឹងថានឹងថយចុះ ២,៥% ធៀបនឹងឆ្នាំ២០២១។ បញ្ហាគ្រោះមហន្តរាយពាក់ព័ន្ធនឹងធាតុអាកាសក្តៅខ្លាំពេកនៅតំបន់ដាំដុះគ្រាប់ធញ្ញជាតិលើសកលលោកក្នុងខែវិច្ឆិកា ដែលជំរុញដោយអាកាសធាតុប្រែប្រួល បានដាក់សម្ពាធលើផលិកម្ម និងតម្លៃនៃផលិតផលកសិកម្មលើសកលលោក។

**វិបត្តិស្បៀងអាហារពិភពលោក ត្រូវបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរមួយផ្នែក ដោយការរឹតបន្តឹងពាណិជ្ជកម្មស្បៀងអាហារ**ដែលដាក់ដោយប្រទេសមួយចំនួនដើម្បីបង្កើនការផ្គត់ផ្គង់ក្នុងស្រុក និងកាត់បន្ថយតម្លៃ។

គិតត្រឹមខែធ្នូឆ្នាំ២០២២ ប្រទេសចំនួន ១៩ បានជំរុញឱ្យមានការហាមឃាត់ការនាំចេញអាហារចំនួន២៣ ហើយប្រទេសចំនួន ៨ បានអនុវត្តវិធានការកំណត់ការនាំចេញចំនួន ១២ ។

**បញ្ហានេះមិនបានកើតឡើងដាច់ដោយឡែកនៅទេ។** កូវីដ-១៩បានប៉ះពាល់ជាអវិជ្ជមានដល់ប្រាក់ចំណូល និងតម្រូវការគ្រួសារ ជាហេតុធ្វើឲ្យមានឧបសគ្គដល់ខ្សែច្រវ៉ាក់ផ្គត់ផ្គង់សកល កើនឡើងអតិផរណា និងបំណុលក្នុងប្រទេសជាច្រើន-ធ្វើឲ្យរំខានដល់ការស្តារសេដ្ឋកិច្ចពីការរាតត្បាតកូវីដ-១៩។ ភស្តុតាងចង្អុលបង្ហាញពីស្ថានភាពសន្តិសុខស្បៀងដែលមិនស្ថិតស្ថេរក្នុងចំណោមគ្រួសារកម្ពុជា ជាពិសេសសម្រាប់អ្នកដែលងាយរងគ្រោះបំផុតនិងអ្នកដែលរស់នៅក្នុងតំបន់ដែលងាយរងគ្រោះដោយទឹកជំនន់

**ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក កម្ពុជាជាប្រទេសប្រឈមខ្លាំងទៅនឹងការកើនឡើងតម្លៃថាមពល** ដោយសារតែការនាំចូលឥន្ធនៈខ្ពស់ធៀបនឹង GDP ការប្រើប្រាស់អគ្គិសនីក្នុងស្រុកនៅមានកម្រិត និងការពឹងលើឥន្ធនៈផូស៊ីល។ ជាការពិត ការឡើងថ្លៃប្រេង គួបផ្សំនឹងការធ្លាក់ចុះនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក និងចិនដែលជាដៃគូពាណិជ្ជកម្មដ៏ធំរបស់កម្ពុជា ជាកត្តាសំខាន់រារាំងកំណើនសេដ្ឋកិច្ចរបស់កម្ពុជា ដែលបានព្យាករណ៍នៅត្រឹម ៥,០% សម្រាប់ឆ្នាំ២០២២ និង៥,៩% សម្រាប់ឆ្នាំ២០២៣។

**ដើម្បីស្វែងយល់ពីឥទ្ធិពលនៃបញ្ហាទាំងនេះ** លើភាពមានស្បៀង និងលទ្ធភាពទទួលបានស្បៀងនៅតាមផ្សារនានា ក្នុងប្រទេសកម្ពុជា កម្មវិធីស្បៀងអាហារពិភពលោក (WFP) សហការជាមួយការិយាល័យទីផ្សារកសិកម្ម (AMO) តាមដានតម្លៃលក់រាយ និងលក់ដុំ របស់ស្បៀងអាហារសំខាន់ៗ នៅក្នុងផ្សារចំនួន៥៦ ទាំងនៅទីប្រជុំជន និងជនបទទូទាំងប្រទេស (សូមមើលផ្នែកវិធីសាស្រ្ត)។ ប្រធានផ្សារក៏ត្រូវបានសម្ភាសន៍ផងដែរ ដើម្បីវាយតម្លៃពីដំណើរការរបស៍ទីផ្សារ ទាំងបញ្ហាផ្គត់ផ្គង់ស្បៀង និងតម្រូវការស្បៀង។ ជាមធ្យម ប្រធានផ្សារ និងអាជីវករចំនួ័ន ១.០០០ នាក់ ត្រូវបានសម្ភាសន៍ជារៀងរាល់ពីរសប្តាហ៍។

# មាតិកា


១. **របកគំហើញសំខាន់ៗ** ៣

២. **លទ្ធផល**

ការដំណើរការរបស់ផ្សារៈ ទិដ្ឋភាពទូទៅ ៤

ការទៅផ្សារៈទិន្នាការអតិថិជន ៥

ថ្នាក់ជាតិៈ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ៦

ថ្នាក់ក្រោមជាតិៈ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ៧

ថ្នាក់ជាតិៈ និន្នាការតម្លៃអង្ករចម្រុះ ស៊ុតទានិងត្រកួន ៨

ថ្នាក់ជាតិៈ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា ៩

ថ្នាក់ក្រោមជាតិៈ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ និងទីប្រជុំជន ១០

ការតាមដានរដូវកាលៈ របាយទឹកភ្លៀង ១១

ការតាមដានរដូវកាលៈ ស្ថានភាពរុក្ខជាតិនិងដំណាំ ១២

៣. **បរិបទ**

ពាណិជ្ជកម្ម ១៣

ការឆ្លើយតបផ្នែកនយោបាយ ១៤

៤. **វិធីសាស្រ្ត និងទីតាំងផ្សារ** ១៥

៥. **ឧបសម្ព័ន្ធទី១**

បម្រែបម្រួលថ្លៃលក់រាយ ១៦

៦. **ឧបសម្ព័ន្ធទី២**

បម្រែបម្រួលថ្លៃលក់ដុំ ១៧

៧. **ឧបសម្ព័ន្ធទី៣**

តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ១៨

## កត្តាបរិស្ថានដែលមានឥទ្ធិពលលើតម្លៃ

**កំណើនសេដ្ឋកិច្ច**

| ២០២១ | ២០២២ |
|---|---|
| ៣,០% | ៥,០%* |

**អតិផរណា**

| CPI វិច្ឆិកា ២០២២ | CPI ធ្នូ ២០២២ |
|---|---|
| ១៩៨,៣ | ១៩៧,៥ |

*IMF ព្យាករអត្រាអតិផរណានៅកម្ពុជាថាកើនដល់ <u>៥,៨% នៅឆ្នាំ២០២២ និង ៣,៥% នៅឆ្នាំ២០២៣</u>។ ក្នុងខែធ្នូ ឆ្នាំ ២០២២ សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់រួម (CPI)បានថយចុះ 0,៤% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង២,៩%ធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន។ គ្រួសារ កម្ពុជាចំណាយស្ទើរតែពាក់កណ្តាល (៤៨,៧%) នៃប្រាក់ចំណូលរបស់ខ្លួនលើស្បៀងអាហារ (៦0% សម្រាប់គ្រួសារក្រីក្រ) ( CSES ២០១៩/២០២០)។*

**ការព្យាករណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិ*




***<u>សន្ទស្សន៍តម្លៃស្បៀងអាហារសកលរបស់ FAO (FFPI)</u>បង្ហាញនិន្នាការថយចុះ ក្នុងរយៈពេល២-៣ខែចុងក្រោយនៃឆ្នាំ២០២២។*** *ក្នុងខែធ្នូ ឆ្នាំ២០២២ FFPI ស្មើនឹង ១៣២,៤ ហើយវាបានថយចុះ ១,៩% ធៀបនឹងខែមុន និង ១,0% ធៀបនឹងខែដូចគ្នាក្នុងឆ្នាំមុន។ **សន្ទស្សន៍តម្លៃស្បៀងអាហារកម្ពុជា (FPI)** ក្នុងខែធ្នូ ឆ្នាំ២០២២ បានថយចុះ 0,២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៣,៨% ធៀបនឹងខែដដែលកាលពីឆ្នាំមុន។*




***<u>តម្លៃលក់រាយប្រេងសាំង (ធម្មតា) និងប្រេងម៉ាស៊ូតបានធ្លាក់ចុះយ៉ាងខ្លាំងក្នុងខែធ្នូ ឆ្នាំ២០២២។</u>*** *តម្លៃលក់រាយប្រេងសាំង (ធម្មតា) បានថយចុះ ៥,0% និងប្រេងម៉ាស៊ូតក៏បានធ្លាក់ចុះដែរ ១0,៨% ធៀបនឹងខែវិច្ឆិកា។ ទោះយ៉ាងណា បើធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុនវិញ តម្លៃប្រេងម៉ាស៊ូតនៅតែខ្ពស់ (+១៩,៣ %) ហើយ**ប្រហែលនៅតែមានឥទ្ធិពលអវិជ្ជមានលើផលិតកម្ម និងតម្លៃស្បៀង**។ ផ្ទុយទៅវិញ ប្រេងសាំង មានតម្លៃប្រហាក់ប្រហែលនឹងឆ្នាំមុន។*

មករា កុម្ភៈ មីនា មេសា ឧសភា មិថុនា កក្កដា សីហា កញ្ញា តុលា វិច្ឆិកា ធ្នូ ២០២២

# សង្ខេបរបកគំហើញសំខាន់ៗ

នៅក្នុងខែធ្នូ ឆ្នាំ២០២២ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របស់ WFP បន្ទាប់ពីឡើងដល់តម្លៃខ្ពស់បំផុតក្នុងខែតុលាបានបន្តធ្លាក់ចុះ ចំពេលដែលតម្លៃស្បៀងអាហារ និងប្រេងឥន្ធនៈលើសកលធ្លាក់ចុះ។ បើប្រៀបធៀបទៅនឹងខែមុន (MoM) ការចំណាយរបស់ BFB បានធ្លាក់ចុះ ២,៧% និងមានតម្លៃថោកជាង ១,៩% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន (YoY) ដែលស្មើនឹង២៦,៦ ដុល្លារ។ . តម្លៃម្ហូបអាហារបានធ្លាក់ចុះនៅក្នុងតំបន់ជនបទជាមួយនឹងតម្លៃមធ្យមនៃ BFB គឺ ២៥,៧ ដុល្លារ (-៥.៣% MoM) ទាបជាងនៅក្នុងតំបន់ទីប្រជុំជនដែលតម្លៃស្មើនឹង ២៧,0 ដុល្លារ (-១,៣% MoM)។

តម្លៃនៃទំនិញស្បៀងអាហារទាំងអស់នៅក្នុងកញ្ចប់ បានធ្លាក់ចុះក្នុងខែធ្នូ រួមមាន៖ ស៊ុតទា (-១0,២% MoM), ត្រកួន (-៤,៥% MoM) សាច់ជ្រូក (-៣,៥% MoM) អង្ករចម្រុះ (-២,១% MoM) ប្រេងឆា (-១,៤% MoM) និងត្រីផ្ទក់ (-0,៣% MoM) ។ ការបន្ធូរបន្ថយតម្លៃស្បៀងអាចជាប់ទាក់ទងទៅនឹងការធ្លាក់ចុះនៃតម្លៃប្រេងឥន្ធនៈ ការបន្តប្រមូលផលស្រូវវស្សា និងការចាប់ផ្តើមរដូវនេសាទត្រីទឹកសាប។ តម្លៃនៃស្បៀងអាហារភាគច្រើនមានកម្រិតប្រហាក់ប្រហែលកាលពីឆ្នាំមុន លើកលែងតែពងទា (+១៤,៨% YoY) និងត្រីពស់ (+៨,១% YoY)។

បន្ទាប់ពីល្អប្រសើរខ្លាំងក្នុងខែវិច្ឆិកា ដំណើរការរបស់ផ្សារបានធ្លាក់ចុះបន្តិចទំនងដោយសារភាពមិនគួរឱ្យទុកចិត្តនៃស្ថិរភាពតម្លៃ និងការព្យាករណ៍តម្លៃ ចំពេលមានការធ្លាក់ចុះនៃតម្លៃប្រេងឥន្ធនៈ ការកើនឡើងនៃតម្រូវការអ្នកប្រើប្រាស់ក្នុងអំឡុងពេលថ្ងៃឈប់សម្រាកចុងឆ្នាំ និងការកើនឡើងនៃករណីឆ្លង COVID-19 នៅក្នុងប្រទេស និងតំបន់។

កំឡុងពេលតម្លៃប្រេងម៉ាស៊ូត ដែលជាប្រភពថាមពលដ៏សារៈសំខាន់ចំពោះផលិតកម្មកសិកម្ម និងតម្លៃជីកសិកម្ម ក្នុងស្រុកនៅតែខ្ពស់ជាបន្តបន្ទាប់ គោលដៅជាតិសម្រាប់ផលិតកម្មស្បៀងក្នុងស្រុកប្រហែលជាមិនអាចសម្រេចបានទេ។ របាយការណ៍ផ្លូវការបង្ហាញពីការថយចុះនៃផ្ទៃដីដាំដុះ និងទិន្នផលទាបនៃស្រូវរដូវវស្សាក្នុងឆ្នាំ២០២២ ធៀបនឹងឆ្នាំ២០២១។ លើសពីនេះ ភស្តុតាងពីការស្ទង់មតិភាពងាយរងគ្រោះរបស់ WFP ចង្អុលបង្ហាញអំពីការធ្លាក់ចុះនៃសន្តិសុខស្បៀងក្នុងគ្រួសារនៅឆ្នាំ២០២២។

# ការដំណើរការរបស់ផ្សារ

សន្ទស្សន៍ដំណើរការផ្សារ (MFI)[1] វាស់វែងពីដំណើរការរបស់ផ្សារដែលបានតាមដាន ដោយផ្អែកលើសមាសធាតុសំខាន់ៗ៖ ភាពចម្រុះនៃទំនិញចាំបាច់ ភាពអាចរកបានជាក់ស្តែងនៃទំនិញក្នុងបរិមាណគ្រប់គ្រាន់ តម្លៃដែលអាចព្យាករបាននិងមានស្ថេរភាព និងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់។ ពិន្ទុ MFI នៅចន្លោះពី០ ដល់១០ ដែលពិន្ទុកាន់តែខ្ពស់បង្ហាញពីដំណើរការកាន់តែល្អ។

ក្នុងខែធ្នូ ឆ្នាំ២០២២ ដំណើរការរបស់ផ្សារបានធ្លាក់ចុះបន្តិច បើប្រៀបធៀបទៅនឹងខែមុន។ ការធ្លាក់ចុះនេះអាចមកពីភាពមិនច្បាស់លាស់នៃស្ថិរភាពតម្លៃ និងការព្យាករណ៍តម្លៃសម្រាប់ទំនិញសំខាន់ៗភាគច្រើន ដែលទំនងជាបណ្តាលមកពីការធ្លាក់ចុះនៃតម្លៃប្រេងឥន្ធនៈជាបន្តបន្ទាប់ កើនឡើងតម្រូវការក្នុងអំឡុងពេលថ្ងៃឈប់សម្រាកចុងឆ្នាំ និងការកើនឡើងនៃករណីឆ្លង COVID-19 នៅក្នុងប្រទេស និងតំបន់។ ប្រហែល ៣,៦% នៃប្រធានទីផ្សារ និងអ្នកលក់ដែលបានសម្ភាស បានរាយការណ៍ពីការកើនឡើងតម្លៃផ្គត់ផ្គង់ក្នុងខែធ្នូ ខណៈពេលដែលមិនមានការរបាយការណ៍នៅក្នុងខែវិច្ឆិកា។




*[1]សមាសធាតុទាំងបួន ដូចជា ភាពចម្រុះនៃទំនិញ ភាពមានស្បៀង តម្លៃស្បៀង និងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់នៅក្នុងសន្ទស្សន៍ដំណើរការផ្សារសង្ខេប គឺជាសន្ទស្សន៍ ដែលមានពីលេខ០ ដល់លេខ១០ ហើយតម្លៃកាន់តែខ្ពស់បង្ហាញថា ផ្សារមានដំណើរការកាន់តែល្អកំឡុងពេលតាមដាន។ សន្ទស្សន៍ដំណើរការផ្សារជារួមគឺជាការបញ្ចូលគ្នានៃសមាសធាតុទាំងបួន។ លម្អិតពីវិធីសាស្ត្ររបស់សន្ទស្សន៍ដំណើរការផ្សារ។ ចាប់ពីពាក់កណ្តាលខែកញ្ញា ឆ្នាំ២០២២មក ព័ត៌មានស្តីពីទំនិញមិនមែនស្បៀងអាហារក៏ត្រូវបានបញ្ចូលទៅក្នុងការវិភាគនេះដែរ។*

# ការទៅផ្សារ៖ ទិន្នាការអតិថិជន

ប្រធានផ្សារ និងអ្នកលក់តាមបណ្តាផ្សារទាំង៥៦ (ផ្សារចំនួន១១ ទើបបន្ថែមក្នុងខែកញ្ញា) ដែលបានតាមដានតម្លៃនៅក្នុងប្រទេសកម្ពុជាត្រូវបានសម្ភាសន៍ស្តីពីភាពងាយស្រួលក្នុងការធ្វើដំណើរទៅផ្សារ និងចំនួនអតិថិជនទៅផ្សាររបស់ពួកគាត់នៅសប្តាហ៍ទី១ និងសប្តាហ៍ទី៣ នៃខែនីមួយៗ។

ចំនួនអតិថិជនបានទៅផ្សារបានចាប់ផ្តើមកើនឡើងជាលំដាប់នៅក្នុងខែធ្នូ ដែលទំនងដោយសារតែការកើនឡើងនៃតម្រូវការរបស់អ្នកប្រើប្រាស់ក្នុងអំឡុងពេលថ្ងៃឈប់សម្រាកចុងឆ្នាំ និងការធ្លាក់ចុះនៃតម្លៃប្រេងឥន្ធនៈជួយកាត់បន្ថយការចំណាយគ្រួសារលើការដឹកជញ្ជូន។




បម្រែបម្រួល[1]នៃចំនួនអតិថិជនមកផ្សារ

*[1]តម្លៃលេខបង្ហាញពីបម្រែបម្រួលនៃចំនួនអតិថិជនត្រូវបានគណនាដោយប្រើសន្ទស្សន៍កំណើន/តំហាយ (diffusion index) ដើម្បីតាមដានពីការប្រែប្រួលអតិថិជនមកផ្សារក្នុងស៊េរីពេលវេលា។*

# ថ្នាក់ជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របស់ WFP ត្រូវបានគណនាដើម្បីជាជំនួយក្នុងការបកស្រាយផលប៉ះពាល់នៃការប្រែប្រួលតម្លៃស្បៀងប្រចាំខែលើតម្លៃរបបអាហារប្រកបដោយអាហារូបត្ថម្ភដែលបានទទួលទាននៅកម្ពុជា។

ក្នុងខែធ្នូ ឆ្នាំ២០២២ តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានបានធ្លាក់ចុះ ២,៧% ធៀបនឹងខែមុន និង១,៩% ធៀបនឹងឆ្នាំមុន ដល់តម្លៃ ១០៨.៩០១ រៀល/ម្នាក់/ខែ (ប្រហែល ២៦,៦ ដុល្លារ)។ តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានមានតម្លៃខ្ពស់ជាងបន្តិចនៅទីប្រជុំជន (២៧,០ ដុល្លារ) បើធៀបនឹងជនបទ (២៥,៧ ដុល្លារ)។




## កញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របបអាហារប្រចាំថ្ងៃសម្រាប់មនុស្សម្នាក់



*កញ្ចប់ស្បៀងអាហារមូលដ្ឋានមានបញ្ចូលនូវស្បៀងអាហារសំខាន់ៗ រួមមាន អង្ករចម្រុះ ត្រីផ្អក់ សាច់ជ្រូក ស៊ុតទា ប្រេងឆា ដំឡូងជ្វា និងត្រកួន ដែលផ្តល់ថាមពលអប្បបរមាចាំបាច់ចំនួន ១.៩៣៧ កាឡូរី សម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ។ កញ្ចប់ស្បៀងអាហារមូលដ្ឋានត្រូវបានវិភាគដោយផ្អែកលើកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា របស់ WFP។ សូមមើលឧបសម្ព័ន្ធទី៣ សម្រាប់ព័ត៌មានពីវិធីសាស្រ្ត។*

# **ថ្នាក់ក្រោមជាតិ៖** តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របស់ WFP មានការប្រែប្រួលទៅតាមខេត្ត និងផ្សារ។ តម្លៃកញ្ចប់ស្បៀងអាហារខ្ពស់ជាងគេស្ថិតនៅផ្សារសាមគ្គី ក្នុងខេត្តកំពត គឺ ១៣៥.៥៤៦ រៀល/ម្នាក់/ខែ (ប្រហែល ៣៣,១ ដុល្លារ) ដែលខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិ ២៤,៥%។ តម្លៃ BFB ទាបជាងគេស្ថិតក្នុងផ្សារស្ទោង ក្នុងខេត្តកំពង់ធំ និងផ្សារឈើកាច់ ក្នុងខេត្តព្រៃវែង គឺ ៩៦.៥០០ រៀល/ម្នាក់/ខែ (ប្រហែល ២៣,៥ ដុល្លារ) ដែលទាបជាងតម្លៃមធ្យមថ្នាក់ជាតិ១១,៤%។ ផែនទីខាងក្រោមបង្ហាញពីតម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន នឹងបម្រែបម្រួលធៀបនឹងតម្លៃកញ្ចប់មធ្យមថ្នាក់ជាតិ។

តម្លៃកញ្ចប់ស្បៀងអាហារបម្រែបម្រួលខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិ ចាប់ពី៥% ឬខ្ពស់ជាង ឡើងទៅ គឺភាគច្រើនមាននៅផ្សារនៅទីប្រជុំជន ជាងនៅក្នុងផ្សារនៅជនបទ។

**តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានតាមផ្សារ ឬខេត្ត ធៀបនឹងតម្លៃកញ្ចប់ជាមធ្យមថ្នាក់ជាតិ (ខែធ្នូ ឆ្នាំ២០២២)**




| បម្រែបម្រួលពីតម្លៃមធ្យមថ្នាក់ជាតិ | ភាគរយនៃផ្សារនៅ ជនបទ | ភាគរយនៃផ្សារនៅ ទីប្រជុំជន |
|---|---|---|
| ≥ ១០% ខ្ពស់ជាង | ០,០% | ១០០% |
| ៥% ទៅ ១០% ខ្ពស់ជាង | ៤០,០% | ៦០,០% |
| < ៥% ខ្ពស់ជាង | ៤១,៧% | ៥៨,៣% |
| < ៥% ទាបជាង | ៤៧,១% | ៥២,៩% |
| ៥% ទៅ ១០% ទាបជាង | ៥០,០% | ៥០,០% |
| ≥ ១០% ទាបជាង | ៦៦,៧% | ៣៣,៣% |

# ថ្នាក់ជាតិ៖ និន្នាការតម្លៃអង្ករ ស៊ុតទា និងត្រកួន

ក្នុងខែធ្នូ ឆ្នាំ២០២២ តម្លៃពងទា តម្លៃត្រកួន និងតម្លៃអង្ករចម្រុះបានបង្ហាញពីនិន្នាការធ្លាក់ចុះ បើធៀបនឹងខែមុន។ បន្ទាប់ពីការកើនឡើងដល់កម្រិតខ្ពស់បំផុតក្នុងខែវិច្ឆិកា តម្លៃពងទាបានធ្លាក់ចុះគួរឲ្យកត់សម្គាល់ប្រហែល ១០,២% ធៀបនឹងខែមុន ដែលទំនងដោយសារការធ្លាក់ចុះនៃតម្លៃចំណីទា (ភាគច្រើនស្រូវ) និងការប្រកួតប្រជែងតម្លៃនៃទំនិញសម្បូរប្រូតេអ៊ីនផ្សេងទៀតដូចជាត្រី និងសាច់ជ្រូក។ ប៉ុន្តែ តម្លៃពងទានៅតែខ្ពស់ជាងខែដូចគ្នាកាលពីឆ្នាំមុន ១៩,៨%។ តម្លៃត្រកួនបានបន្តថយចុះចំនួន ៤,៥% ធៀបនឹងខែមុន និង៩,៥% ធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន។ តម្លៃអង្ករចម្រុះបានធ្លាក់ចុះបន្តិច (-២,១% ធៀបនឹងខែមុន និង -0,0% ធៀបនឹងឆ្នាំមុន) ក្នុងខែវិច្ឆិកា ឆ្នាំ២០២២ ដែលប្រហែលដោយសារតែការបន្តប្រមូលផលស្រូវរដូវវស្សា។

*សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃនៃស្បៀងអាហារផ្សេងៗទៀត។*




[1] ត្រកួនគឺបន្លែដែលត្រូវបានទទួលទានជាទូទៅនៅប្រទេសកម្ពុជា ហើយនិន្នាការតម្លៃរបស់វាមិនបង្ហាញពីការឡើងចុះតម្លៃបន្លែផ្សេងទៀតនៅក្នុងឧបសម្ព័ន្ធនោះទេ។

[2] ដោយសារផ្សារត្រូវបានផ្អាកដំណើរការក្នុងកំឡុងពេលបិទខ្ទប់ ចាប់ពីពាក់កណ្តាលខែមេសា ឆ្នាំ២០២១ ទិន្នន័យតម្លៃស្បៀងនៅសប្តាហ៍ទី៣ ខែមេសា និងក្នុងខែឧសភា ឆ្នាំ២០២១ មិនអាចប្រមូលក្នុងផ្សារនៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រះសីហនុ ។

# ថ្នាក់ជាតិ៖ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា

ក្នុងខែធ្នូ ឆ្នាំ២០២២ តម្លៃសាច់ជ្រូក (-៣,៥%) ប្រេងឆា (-១,៤%) និងត្រីផ្ទក់ (-០,៣%) បានថយចុះបន្តិចបន្តួច បើធៀបនឹងខែមុន។ ការធ្លាក់ចុះនៃតម្លៃនេះទំនងដោយសារធ្លាក់ចុះនៃតម្លៃប្រេងឥន្ធនៈ ដែលនាំឱ្យថ្លៃដើមផលិតកម្ម និងតម្លៃនៃការដឹកជញ្ជូនស្បៀងអាហារថយចុះ។ ប្រេងឆាមានតម្លៃប្រហាក់ប្រហែលនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១ (+១,៩%) ខណៈដែលតម្លៃសាច់ជ្រូកទាបជាងកាលឆ្នាំមុនចំនួន ១១,៦%។ ទោះយ៉ាងណា ត្រីផ្ទក់នៅតែមានតម្លៃខ្ពស់ជាងនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១ ចំនួន៨,៩%។

*សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃស្បៀងអាហារផ្សេងៗទៀត។*




[1] *ដោយសារផ្សារត្រូវបានផ្អាកដំណើរការក្នុងកំឡុងពេលបិទខ្ទប់ ចាប់ពីពាក់កណ្តាលខែមេសា ឆ្នាំ២០២១ ទិន្នន័យតម្លៃស្បៀងនៅសប្តាហ៍ទី៣ ខែមេសា និងក្នុងខែឧសភា ឆ្នាំ២០២១ មិនអាចប្រមូលក្នុងផ្សារនៅរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រះសីហនុ ។*

# ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ និងទីប្រជុំជន

នៅក្នុងខែធ្នូ ឆ្នាំ២០២២ ស្បៀងអាហារសំខាន់ៗភាគច្រើនក្នុងចំណោមសរុបទាំងអស់៧មុខ ដែលបានកំពុងតាមដាន នៅទីប្រជុំជនមានតម្លៃមធ្យមលក់រាយខ្ពស់ជាងនៅជនបទ លើកលែងពងទា និងប្រេងឆា (តារាង១)។

តម្លៃមធ្យមលក់រាយអង្ករចម្រុះ ត្រីផ្ទក់ សាច់ជ្រូក ប្រេងឆា និងជំឡូងផ្វាពណ៌លឿង មានបម្រែបម្រួលតិចតួច (< ៥,០%) និងមានទិសដៅបម្រែបម្រួលដូច (លើកលែងតែត្រីផ្ទក់) ទាំងនៅទីប្រជុំជន និងទីជនបទ បើធៀបនឹងខែមុន។ ធៀបនឹងខែវិច្ឆិកា តម្លៃលក់រាយពងទា និងតម្លៃលក់រាយត្រកួន បានថយចុះយ៉ាងខ្លាំងចំនួន ៩,៦% និង១២,១% រៀងគ្នា នៅជនបទ ហើយក៏បានធ្លាក់ចុះចំនួន ១០,៦% និង០,៧% រៀងគ្នា នៅទីប្រជុំជនផងដែរ។

**តារាង១៖ តម្លៃលក់រាយ (រៀល) នៅជនបទ និងទីប្រជុំជន**

| | ទីប្រជុំជន | ជនបទ |
|---|---|---|
| អង្ករ (គក) | ២.០៦៤ | ២.០៤៤ |
| ត្រីផ្ទក់ (រស់) (គក) | ១០.៨០៨ | ១០.៣២៣ |
| សាច់ជ្រូក (គក) | ១៦.៧៥៤ | ១៦.២៥៨ |
| ស៊ុតទា (១០គ្រាប់) | ៥.៦៥៧ | ៥.៦៨៤ |
| ប្រេងឆា (៥លីត្រ) | ៣១.១៧៤ | ៣១.៥១៧ |
| ត្រកួន (គក) | ៣.៧៧៩ | ៣.៣៧១ |
| ដំឡូងផ្វាពណ៌លឿង | ២.៧១៨ | ២.២៨៣ |

## បម្រែបម្រួលប្រចាំខែ (%) នៃតម្លៃលក់រាយស្បៀងអាហារសំខាន់ៗ

### ខែវិច្ឆិកា ឆ្នាំ២០២២ និងខែធ្នូ ឆ្នាំ២០២២




*សម្គាល់៖ ទិន្នន័យនេះទទួលបានពីផ្សារចំនួន៥៦។ សូមមើលផ្នែកវិធីសាស្ត្រសម្រាប់ព័ត៌មានលម្អិត។*

# ការតាមដានរដូវកាល៖ របាយទឹកភ្លៀង

កម្ពស់ទឹកភ្លៀងជាមធ្យមថ្នាក់ជាតិសរុបចាប់ពីខែតុលា ដល់ខែធ្នូ ឆ្នាំ២០២២ មានកម្រិតខ្ពស់ជាងមធ្យមភាគច្រើនឆ្នាំ ដែលនេះបណ្តាលមកពីទឹកភ្លៀងធ្លាក់ច្រើនជាងមធ្យមភាគច្រើនឆ្នាំនៅក្នុងខែតុលា ចុងខែវិច្ឆិកា និងដើមខែធ្នូ (ក្រាហ្វិកខាងក្រោមខាងឆ្វេង)។ ទោះបីយ៉ាងណា ក្នុងខែធ្នូ របាយទឹកភ្លៀងធ្លាក់មិនទៀងទាត់ និងមិនស្មើនៅទូទាំងប្រទេស (ផែនទីខាងក្រោមខាងស្តាំ)។ ទឹកភ្លៀងធ្លាក់ពីតិចទៅមធ្យមលើសកម្រិតមធ្យមភាគច្រើនឆ្នាំនៅតំបន់ចាប់ពីភាគខាងត្បូង ទៅភាគឦសាននៃប្រទេស ខណៈតំបន់ភាគច្រើននៃខេត្តជុំវិញបឹងទន្លេសាប និងនៅភាគខាងជើង មានទឹកភ្លៀងធ្លាក់ពីកម្រិតធម្មតា ទៅតិចជាងមធ្យមភាគច្រើនឆ្នាំង។

យោងតាមព័ត៌មានព្យាករណ៍តាមរដូវកាលរបស់ IRI Columbia University នៅទាំងប្រទេសត្រូវបានរំពឹងថានឹងទទួលបានទឹកភ្លៀងលើសពីកម្រិតធម្មតាក្នុងកំឡុងរយៈពេល ៣ខែខាងមុខចាប់ពីខែមករា ដល់ខែមីនា ឆ្នាំ២០២៣។ លក្ខខណ្ឌនេះនឹងអំណោយផលសម្រាប់ការដាំដុះស្រូវរដូវប្រាំង ជាពិសេសក្នុងដំណាក់កាលលូតលាស់ និងកំណកំណើត ដំបូង។ ទោះយ៉ាងណាក៏ដោយ ភ្លៀងធ្លាក់ច្រើនលើសលុប បណ្តាលឲ្យជាំទឹក ជាពិសេសក្នុងដំណាក់កាលចេញផ្កា អាចប៉ះពាល់ជាអវិជ្ជមានដល់ដំណាំ និងធ្វើឱ្យបាត់បង់ទិន្នផល។

### បរិមាណទឹកភ្លៀងមធ្យមថ្នាក់ជាតិ (គិតត្រឹមខែធ្នូ ឆ្នាំ២០២២) និងប្រតិទិនដាំដុះតាមរដូវកាល




| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ស្រូវរដូវប្រាំង | ដាំដុះ | | ប្រមូលផល | | | | | | | | រៀបចំដី និង សាបព្រោះ | |
| ស្រូវរដូវវស្សា | ប្រមូលផល | | | | រៀបចំដី និង សាបព្រោះ | | ស្ទូង / ដាំដុះ | | | | ប្រមូលផល | |

*ប្រភព៖ ទិន្នន័យទឹកភ្លៀងពី CHIRPS និងវិភាគដោយ WFP*

### ភាពមិនប្រក្រតីនៃទឹកភ្លៀង ក្នុងខែធ្នូ ឆ្នាំ២០២២




*ប្រភព៖ ទិន្នន័យទឹកភ្លៀងពី CHIRPS និងវិភាគដោយ WFP*

# ការតាមដានរដូវកាល៖ ស្ថានភាពរុក្ខជាតិ និងដំណាំ

នៅក្នុងខែធ្នូ ឆ្នាំ២០២២ ស្ថានភាពរុក្ខជាតិនៅទូទាំងប្រទេស គឺទាបជាងកម្រិតធម្មតា ជាពិសេសតំបន់ក្នុងខេត្តជុំវិញបឹងទន្លេសាប និងភាគខាងជើងនៃប្រទេស ដែលទំនងជាវាលស្រែទំនេរបន្ទាប់ពីប្រមូលផលស្រូវរដូវវស្សារួច និង/ឬទឹកភ្លៀងធ្លាក់តិចតួច (ផែនទីនៅខាងស្តាំ )។ ផ្ទុយទៅវិញ ស្ថានភាពរុក្ខជាតិដែលមានសុខភាពល្អ ត្រូវបានអង្កេតឃើញនៅតាមតំបន់ ដែលដាំដុះស្រូវរដូវប្រាំងច្រើន រួមមានដូចជា៖ ខេត្តព្រៃវែង ខេត្តតាកែវ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ។

គិតត្រឹមខែធ្នូ ឆ្នាំ២០២២ ដំណាំស្រូវរដូវវស្សាកំពុងប្រមូលផលបានរួចរាល់ជិត ៨៣% នៃផ្ទៃដីដាំដុះសរុប (ប្រហែល ២,៣ លានហិកតា) ហើយទទួលបានផលិតផលស្រូវ ស្មើនឹង ៧,៦ លានតោន។ ទន្ទឹមនឹងនោះ ទឹកភ្លៀងច្រើនគ្រប់គាន់ក្នុងរយៈពេលបីខែចុងក្រោយ បានធ្វើឲ្យមានទឹកគ្រប់គ្រាន់ បង្កលក្ខខណ្ឌអំណោយផលដល់ការដាំដុះស្រូវរដូវប្រាំង។ គិតត្រឹមខែធ្នូ ឆ្នាំ២០២២ ការដាំដុះស្រូវរដូវប្រាំងសម្រេចបានប្រមាណ ៤០៣.២៣៣ ហិកតា ស្មើនឹង ៨១.៧% នៃផែនការជាតិប្រចាំឆ្នាំ នេះបើយោងតាមក្រសួងធនធានទឹក និងឧតុនិយម។

**ភាពមិនប្រក្រតីនៃសន្ទស្សន៍ភាពខុសគ្នានៃរុក្ខជាតិ (NDVI)**
**ក្នុងខែធ្នូ ឆ្នាំ២០២២**




*ប្រភព៖ NDVI ពី MODIS និងវិភាគដោយ WFP*
*ចំណាំ៖ ការបកស្រាយពីស្ថានភាពរុក្ខជាតិមានកម្រិតសម្រាប់តំបន់គ្របដណ្តប ដោយពពកឬមិនមានទន្និន័យ*

# ពាណិជ្ជកម្ម

ស្ថិតិសរុបនៃពាណិជ្ជកម្មនៅតែបង្ហាញវឌ្ឍនភាពជាវិជ្ជមាន។ ការនាំចេញផ្លូវការសរុបរបស់កម្ពុជាមានតម្លៃ ២២,៥៨ ពាន់លានដុល្លារ ក្នុងឆ្នាំ២០២២ ដែលខ្ពស់ជាងរយៈពេលដដែលកាលពីឆ្នាំមុនប្រមាណ១៦,៥%។ ក្នុងចំណោមមុខទំនិញនាំចេញទាំងអស់ ផលិតផលកសិកម្មសរុបចំនួន ៨,២ លានតោនត្រូវបាននាំចេញចាប់ពីខែមករា ដល់ខែវិច្ឆិកាក្នុងឆ្នាំ២០២២ (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី៥ ខែមករា ឆ្នាំ២០២៣)។ យោងតាមសហព័ន្ធស្រូវអង្ករកម្ពុជា ការនាំចេញអង្ករមានចំនួន ៦៣៧.០០៤ តោន (មានតម្លៃស្មើ ៤១៤,២៩លានដុល្លារ) ក្នុងឆ្នាំ២០២២ បានកើនឡើង ៣,២% ធៀបនឹងរយៈពេលដដែលកាលពីឆ្នាំមុន។ បន្ថែមលើការនាំចេញអង្ករ ការនាំចេញស្រូវមានចំនួន ៣,៥៨ លានតោន (មានតម្លៃ ៨៥១,១ លានដុល្លារ) ក្នុងរយៈពេលដូចគ្នា។

នៅក្នុងឆ្នាំ២០២២ ប្រទេសកម្ពុជាបាននាំចូលជាផ្លូវការសរុបមានតម្លៃ ២៩,៨៥ ពាន់លានដុល្លារ ដែលរួមមាន៖ ធញ្ញជាតិសរុបចំនួន ៥៧,៨ លានដុល្លារ (-៣៧,៣% ធៀបឆ្នាំមុន) និងអាហារដទៃទៀត (ដូចជា៖ សាច់/សំណល់សាច់/គ្រឿងក្នុងដែលអាចបរិភោគបានបន្លែដែលអាចបរិភោគបាន ឫស/មើម និងខ្លាញ់សត្វ ប្រេងរុក្ខជាតិ) ចំនួន ១.០៨៣,៧ លានដុល្លារ (+១៦,៧%)។ ប្រទេសកម្ពុជាក៏បាននាំចូលជីកសិកម្មចំនួន ២៧៦,៥ លានដុល្លារ (-៣,៦% ធៀបឆ្នាំមុន) គិតត្រឹមខែធ្នូ ឆ្នាំ២០២២។

លើសពីនេះ ប្រទេសកម្ពុជាបានទទួលការវិនិយោគពីបរទេសក្នុងទំហំទឹកប្រាក់ ៤,៦៨ ពាន់លានដុល្លារក្នុងឆ្នាំ២០២២ ដែលខ្ពស់ជាងកាលពីឆ្នាំមុនចំនួន ៧,៥% យោងតាមក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី៧ ខែមករា ឆ្នាំ ២០២៣)។ គម្រោងវិនិយោគផ្តោតសំខាន់លើវិស័យកសិកម្ម និងកសិឧស្សាហកម្ម ផលិតកម្ម ទេសចរណ៍ និងវិស័យអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ។

នៅក្នុងឆ្នាំ២០២២ កម្ពុជាប្រមូលបាន ៦,១ ពាន់លានដុល្លារលើពន្ធដារគ្រប់ប្រភេទ និងពន្ធគយ ដែលកើនឡើង ២០,៣% បើធៀបនឹងឆ្នាំ ២០២១ (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី ២ ខែមករា ឆ្នាំ ២០២៣)។

ទោះជាយ៉ាងណាក៏ដោយ ការនាំចេញផលិតផលកាត់ដេរ និងស្បែកជើងត្រូវបានគេរំពឹងថានឹងថយចុះក្នុងរយៈពេល ៦ខែដំបូងនៃឆ្នាំ២០២៣ ដោយសារតែការបញ្ជាទិញធ្លាក់ចុះប្រមាណ ៣០% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំមុន (ដកស្រង់ដោយ កាសែតខ្មែរថាមស៍ ថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣)។

## សមតុល្យពាណិជ្ជកម្មកម្ពុជា (គិតជាលានដុល្លារ) នៃក្រុមទំនិញសំខាន់ៗ គិតត្រឹមខែធ្នូ ឆ្នាំ២០២២




*ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ថ្ងៃទី ១១ ខែមករា ឆ្នាំ២០២៣*

# ការឆ្លើយតបផ្នែកនយោបាយ

## គោលនយោបាយឆ្លើយតបលើការគាំពារសង្គម

ផែនការស្តារសេដ្ឋកិច្ចពីការរាតត្បាតកូវីដ-១៩ របស់រដ្ឋាភិបាលមានបញ្ចូលនូវវិធានការគាំពារសង្គមនានា។ ចាប់ពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ រដ្ឋាភិបាលបានអនុវត្តកម្មវិធីជាតិជំនួយសាច់ប្រាក់ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ នៅទូទាំងប្រទេស ដែលប៉ះពាល់ដោយការរាតត្បាតកូវីដ-១៩។ គ្រួសារក្រីក្រប្រមាណ ៧០២.៩០៧ គ្រួសារ (ប្រមាណ ២,៨ លាននាក់) បានទទួលសាច់ប្រាក់ឧបត្ថម្ភ សរុបជាទឹកប្រាក់ចំនួន ៨៦៨,៩២ លានដុល្លារ គិតចាប់ពីដំណើរការកម្មវិធីដំបូងនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២។ កម្មវិធីនេះបានជូនដំណឹងដល់គ្រួសារក្រីក្រ និងងាយរងគ្រោះ អញ្ជើញដកសាច់ប្រាក់សម្រាប់ខែវិច្ឆិកា និងធ្នូ ក្នុងឆ្នាំ២០២២ រហូតដល់ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៣ ហើយកម្មវិធីនឹងបន្តពេញមួយឆ្នាំ២០២៣ទៀតផង។

លើសពីនេះ រដ្ឋាភិបាលបានដាក់ឱ្យដំណើរការកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ក្នុងអំឡុងពេលមានសម្ពាធអតិផរណា និងកម្មវិធីជំនួយសង្គមជាសាច់ប្រាក់ជូនគ្រួសារងាយរងហានិភ័យ ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះទឹកជំនន់ ដែលផ្ទេរសាច់ប្រាក់មានបីលើក។ ក្នុងអំឡុងពេលអនុវត្តដំណាក់កាលដំបូងចាប់ផ្តើមនៅថ្ងៃទី១០ ខែធ្នូឆ្នាំ២០២២ បានចំណាយប្រាក់សរុបចំនួន ២០ លានដុល្លារ ដើម្បីផ្ទេរទៅឱ្យគ្រួសារគោលដៅចំនួន ៣៦០.០០០ (ប្រមាណ ១,២៥ លាននាក់)។ ជុំបន្ទាប់នឹងប្រព្រឹត្តទៅនៅខែមេសា និងខែកក្កដា ឆ្នាំ២០២៣។

## គោលនយោបាយឆ្លើយតបផ្នែកសេដ្ឋកិច្ច

ក្រោមក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ ឆ្នាំ២០២១ - ២០២៣ របស់រដ្ឋាភិបាល ប្រាក់កម្ចីចំនួន ៩១.៥២ លានដុល្លារ ត្រូវបានផ្តល់សម្រាប់ការស្តារ និងលើកកម្ពស់វិស័យទេសចរណ៍ និងបដិសណ្ឋារកិច្ច គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។

រដ្ឋាភិបាលកម្ពុជាគ្រោងថវិកាជាតិចំនួន៩,៦៤ ពាន់លានដុល្លារក្នុងឆ្នាំ២០២៣ ដែលខ្ពស់ជាងឆ្នាំមុន ១៣,០%។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដាក់ចេញនូវយុទ្ធសាស្ត្រមួយ ក្នុងគោលបំណងធានាបាននូវតម្លៃស្ថិរភាព និងតម្លៃបន្ថែមខ្ពស់នៃផលិតផលកសិកម្ម សម្រាប់តម្រូវការក្នុងស្រុក និងការនាំចេញ (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣)។

## ការចាក់វ៉ាក់សាំងកូវីដ-១៩

ផ្អែកតាមក្រសួងសុខាភិបាល គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ពលរដ្ឋអាយុលើសពី៣ឆ្នាំ ជាង ១៥,២៤ លាននាក់ (៥០,៥% ជាស្ត្រី) បានទទួលវ៉ាក់សាំងកូវីដ-១៩ យ៉ាងតិចដូសទី១ សម្រេចតាមផែនការថ្នាក់ជាតិ ១០៤,១% (៩៥,២៦% នៃប្រជាជនសរុប)។

ប្រទេសកម្ពុជា បានពង្រឹងយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ដើម្បីធានាដល់ប្រជាពលរដ្ឋ ទទួលបានកម្រិតមូលដ្ឋាន និងដូសជម្រុញ ខណៈករណីកូវីដ-១៩ កំពុងកើនឡើងទាំងក្នុងប្រទេស និងក្នុងតំបន់។




*ប្រភព៖ ទំព័រហ្វេសប៊ុកផ្លូវការរបស់គាំពារសង្គមកម្ពុជា ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២២*

**ការចាក់វ៉ាក់សាំងកូវីដ-១៩**




*ប្រភព៖ ក្រសួងសុខាភិបាលកម្ពុជា ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២*

# វិធីសាស្ត្រ និងទីតាំងផ្សារ




WFP ចាប់ផ្តើមតាមដានតម្លៃស្បៀងអាហារ នៅតាមបណ្តាផ្សារមួយចំនួនតាមរយៈទូរស័ព្ទ តាំងពីខែវិច្ឆិកា ឆ្នាំ២០១៩ មកម្ល៉េះ។ អ្នកសម្ភាសន៍តាមទូរស័ព្ទ ដែលបានទទួលការបណ្តុះបណ្តាលច្បាស់លាស់បានទំនាក់ទំនងទៅកាន់អាជីវករនានា រៀងរាល់មួយខែម្តង ដើម្បីប្រមូលតម្លៃទំនិញចំនួន៣៦ប្រភេទ ក្នុងផ្សារចំនួន១៩ នៅទីប្រជុំជន និងជនបទនៃខេត្តបាត់ដំបង កំពង់ឆ្នាំង កំពង់ធំ ឧត្តរមានជ័យ សៀមរាប ព្រះវិហារ និងស្ទឹងត្រែង។

នៅក្រោមកិច្ចសហការជាមួយការិយាល័យទីផ្សារកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខែមីនា ឆ្នាំ២០២០ WFP បានអង្កេតតម្លៃទីផ្សារនៅក្នុងផ្សារចំនួន៣១បន្ថែមទៀត ដើម្បីប្រមូលទិន្នន័យមូលដ្ឋាន និងដើម្បីពង្រីកចំនួនផ្សារគ្របដណ្តប់។ យើងបានប្រមូលតម្លៃស្បៀងចំនួន១៦ប្រភេទ និងព័ត៌មានពីដំណើរការរបស់ផ្សារទាំងនោះផងដែរ។

ចាប់ពីពាក់កណ្តាលខែមេសាឆ្នាំ២០២០មក WFP បានពង្រីកការតាមដានតម្លៃទីផ្សារតាមរយៈទូរស័ព្ទក្នុងផ្សារចំនួន៩៥ ហើយក៏បានបង្កើនចំនួនប្រមូលទិន្នន័យ ២ដងក្នុងមួយខែផងដែរ (ឧ. សប្តាហ៍ទី១ និងទី៣នៃខែនីមួយៗ)។

នៅពាក់កណ្តាលខែកញ្ញា ឆ្នាំ២០២២ WFP បន្ថែមទំនិញជាស្បៀងអាហារ និងមិនមែនស្បៀងអាហារចំនួន ១៥ (មើលឧបសម្ព័ន្ធ) និងពង្រីកផ្សារគ្របដណ្តប់ដល់ ៥៦ ផ្សារ។

# ឧបសម្ព័ន្ធទី១៖ បម្រែបម្រួលតម្លៃលក់រាយ

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ១.១ អង្ករចម្រុះ | Kg | 2,055 | → -2.1% | → -2.0% | → 0.9% |
| ២.១ ត្រីផ្ទក់(រស់) | Kg | 10,650 | → -0.3% | → 0.3% | ↑ 8.9% |
| ២.២ ត្រីប្រា(រស់) | Kg | 6,770 | ↓ -7.1% | → -2.1% | ↑ 5.4% |
| ២.៣ ត្រីអណ្តែង(រស់) | Kg | 7,531 | → -4.6% | ↓ -9.1% | → -2.5% |
| ២.៤ ត្រីផ្ទក់ងៀត | Kg | 26,045 | → 3.6% | → 3.3% | ↑ 10.1% |
| ២.៥ ប្រហុក | Kg | 9,726 | ↓ -5.0% | ↓ -8.7% | • |
| ៣.១ សាច់ជ្រូកពពជាន់ | Kg | 16,523 | → -3.5% | ↓ -12.3% | ↓ -11.6% |
| ៣.២ សាច់គោឃារ | Kg | 20,016 | → 2.4% | → -3.7% | • |
| ៣.៣ សាច់មាន់ (បីសាសន៍) | Kg | 13,400 | → 1.6% | ↑ 5.4% | • |
| ៤.១ ស៊ុតទា | 10 eggs | 5,668 | ↓ -10.2% | → -3.1% | ↑ 14.8% |
| ៤.២ ស៊ុតទាប្រៃ | 10 eggs | 7,088 | ↓ -6.1% | → -1.8% | ↑ 9.5% |
| ៥.១ ប្រេងឆា | 5 litres | 31,296 | → -1.4% | → -3.3% | → 1.9% |
| ៦.១ អំបិលម៉ត់អ៊ីយូត | Kg | 1,255 | → -1.3% | → 0.9% | ↑ 9.5% |
| ៦.២ ទឹកត្រី (រូបបង្គងប៉ាក) | 730 ml | 3,356 | → 0.6% | → 3.3% | • |
| ៧.១ សណ្តែកដី* | Kg | 10,214 | → 1.4% | ↑ 6.8% | ↑ 7.2% |
| ៧.២ សណ្តែកសៀង | Kg | 5,582 | ↑ 12.1% | → 1.6% | • |
| ៧.៣ សណ្តែកខៀវ | Kg | 6,004 | → 2.6% | → 1.1% | • |
| ៨.១ ត្រកួន | Kg | 3,643 | → -4.5% | ↑ 15.8% | ↓ -9.5% |
| ៨.២ ការ៉ុត* | Kg | 3,501 | → -1.9% | → -3.8% | ↓ -28.9% |
| ៨.៣ ស្លឹកបាស* | Kg | 5,968 | ↑ 7.6% | ↑ 26.1% | ↑ 10.2% |
| ៨.៤ ស្លឹកម្រុំ* | Kg | 6,175 | ↑ 17.7% | ↑ 10.3% | ↑ 16.9% |
| ៨.៥ ស្ពៃក្រញាញ់* | Kg | 4,948 | → -4.4% | → 4.5% | ↑ 12.6% |
| ៨.៦ ស្ពៃតឿ* | Kg | 4,789 | → 2.6% | → 4.1% | ↑ 7.1% |
| ៨.៧ ស្ពៃចង្កឹះ | Kg | 4,590 | ↑ 13.7% | ↑ 17.3% | ↑ 21.0% |
| ៨.៨ ស្ពៃខៀវ* | Kg | 4,348 | → 3.5% | ↑ 9.9% | ↑ 14.8% |
| ៨.៩ ផ្ទីដូង* | Kg | 4,912 | ↓ -9.1% | ↑ 9.3% | → 0.7% |

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ៨.១០ ស្លឹកងប់* | Kg | 6,860 | ↑ 9.3% | ↑ 30.7% | ↑ 18.4% |
| ៨.១១ ត្រយស្ពៅ* | Kg | 5,676 | → -2.8% | ↑ 15.4% | ↑ 21.8% |
| ៨.១២ ផ្លែស្ពៅ* | Kg | 3,144 | ↑ 6.3% | ↑ 14.1% | ↑ 15.7% |
| ៨.១៣ ឃ្លោក* | Kg | 2,890 | ↓ -5.1% | → 2.2% | ↑ 18.3% |
| ៨.១៤ ត្រឡាច | Kg | 3,469 | → 1.4% | ↑ 25.3% | ↑ 15.4% |
| ៨.១៥ ត្រប់វែង | Kg | 4,635 | ↑ 13.4% | ↑ 36.8% | ↑ 31.4% |
| ៨.១៦ ត្រប់ស្រួយ* | Kg | 4,750 | ↑ 12.9% | ↑ 48.1% | ↑ 14.9% |
| ៨.១៧ ប៉េងប៉ោះ* | Kg | 4,343 | → -3.4% | ↓ -15.8% | ↓ -31.5% |
| ៨.១៨ ននោងមូល | Kg | 3,537 | → -3.3% | → 4.2% | ↑ 20.7% |
| ៨.១៩ ននោងជ្រុង* | Kg | 3,768 | → 1.1% | ↑ 8.3% | ↑ 12.5% |
| ៨.២០ ល្ពៅខ្ញី* | Kg | 1,560 | → 1.4% | ↑ 5.9% | ↑ 14.2% |
| ៨.២១ សណ្តែកគួរ | Kg | 5,428 | ↑ 9.6% | ↑ 37.9% | ↑ 7.6% |
| ៨.២២ ត្រយូងចេក* | Kg | 2,281 | → -2.6% | → 4.7% | → 2.7% |
| ៨.២៣ ផ្កាខាត់ណា* | Kg | 7,547 | ↓ -9.5% | ↓ -17.8% | ↓ -15.7% |
| ៨.២៤ ដើមខាត់ណា* | Kg | 6,545 | → 2.7% | → 3.7% | ↓ -8.6% |
| ៨.២៥ ដំឡូងពណ៌លឿង* | Kg | 2,528 | → 1.4% | → -2.0% | ↑ 16.8% |
| ៨.២៦ ខ្ទឹមសរ | Kg | 5,030 | → -3.4% | ↓ -8.8% | • |
| ៨.២៧ អំពិលទុំ | Kg | 4,208 | → -5.0% | ↓ -5.8% | • |
| ៩.១ ចេកណាំវ៉ាទុំ | Kg | 2,213 | → 4.0% | → 1.2% | • |
| ៩.២ ស្វាយកែវរមៀតទុំ | Kg | 0 | • | • | • |
| ១០.១ ទឹកដោះគោស្រស់ | 140 ml | 1,597 | ↓ -7.2% | ↓ -13.7% | • |
| ១១.១ កូកាកូឡា | 330 ml | 1,941 | → 1.1% | → -1.8% | • |
| ៧.១ សាំងធម្មតា | litre | 4,234 | → -2.7% | ↓ -8.8% | • |
| ៧.២ ម៉ាស៊ូត | litre | 4,612 | ↓ -7.8% | ↓ -10.7% | • |
| ៨.១ ជី៖ អ៊ុយរ៉េ | Kg | 3,601 | → -2.3% | → -3.1% | • |

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍គឺជាតម្លៃជាក់ស្តែង ឧ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

** តម្លៃនៃស្បៀងអាហារទាំងនេះ ត្រូវបានប្រមូលពីផ្សារក្នុងខេត្តដែលអនុវត្តកម្មវិធីផ្តល់អាហារលេតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍។*

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

- ↑ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%
- → ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%
- ↓ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%
- • គ្មានតម្លៃកត់ត្រា

# ឧបសម្ព័ន្ធទី២៖ បម្រែបម្រួលតម្លៃលក់ដុំ

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ១.១ អង្ករចម្រុះ | Kg | 1,911 | → -1.1% | → -1.0% | → 1.1% |
| ២.១ ត្រីផ្ទក់(រស់) | Kg | 9,659 | → 0.4% | → 1.6% | ↑ 9.3% |
| ២.២ ត្រីប្រា(រស់) | Kg | 6,143 | → -3.7% | → 0.7% | ↑ 5.8% |
| ២.៣ ត្រីអណ្តែង(រស់) | Kg | 6,762 | → -3.8% | ↓ -7.8% | → -4.9% |
| ២.៤ ត្រីផ្ទក់ងៀត | Kg | 23,935 | → 2.7% | → 2.6% | ↑ 8.9% |
| ២.៥ ប្រហុក | Kg | 8,590 | ↓ -5.7% | ↓ -6.4% | ● |
| ៣.១ សាច់ជ្រូកពាជាន់ | Kg | 15,185 | → -3.6% | ↓ -12.4% | ↓ -11.3% |
| ៣.២ សាច់គោឃារ | Kg | 18,078 | → 0.9% | → -3.6% | ● |
| ៣.៣ សាច់មាន់ (បីសាសន៍) | Kg | 12,442 | → 4.4% | ↑ 15.1% | ● |
| ៤.១ ស៊ុតទា | 10 eggs | 5,198 | ↓ -11.3% | → -3.3% | ↑ 15.3% |
| ៤.២ ស៊ុតទាប្រៃ | 10 eggs | 6,702 | ↓ -5.7% | → 0.8% | ↑ 12.1% |
| ៥.១ ប្រេងឆា | 5 litres | 30,190 | → -1.4% | → -3.1% | → 0.6% |
| ៦.១ អំបិលម៉ត់អ៊ីយូត | Kg | 1,016 | → 0.3% | → 2.3% | ↑ 7.2% |
| ៦.២ ទឹកត្រី (រូបបង្គងប៉ាក) | 730 ml | 2,974 | → 0.0% | → 4.3% | ● |
| ៧.១ សណ្តែកដី* | Kg | 9,149 | → 0.2% | → 4.3% | → 4.2% |
| ៧.២ សណ្តែកសៀង | Kg | 5,113 | ↑ 9.6% | → 0.9% | ● |
| ៧.៣ សណ្តែកខៀវ | Kg | 5,499 | → 2.3% | → 2.3% | ● |
| ៨.១ ត្រកួន | Kg | 3,291 | ↑ 5.7% | ↑ 28.2% | → -3.1% |
| ៨.២ ការ៉ុត* | Kg | 2,848 | → -2.2% | ↓ -5.3% | ↓ -34.1% |
| ៨.៣ ស្ពៃក្តោប* | Kg | 4,673 | ↑ 6.2% | ↑ 25.5% | → 4.4% |
| ៨.៤ ស្លឹកម្រុំ* | Kg | 4,964 | ↑ 12.6% | ↑ 16.7% | ↑ 6.4% |
| ៨.៥ ស្ពៃក្រញាញ់* | Kg | 4,243 | → -3.7% | ↑ 5.9% | ↑ 12.3% |
| ៨.៦ ស្ពៃតឿ* | Kg | 4,033 | → 4.6% | → 4.9% | ↑ 6.4% |
| ៨.៧ ស្ពៃចង្កឹះ | Kg | 3,840 | ↑ 16.6% | ↑ 22.0% | ↑ 19.1% |
| ៨.៨ ស្ពៃខៀវ* | Kg | 3,619 | → 4.9% | ↑ 14.8% | ↑ 12.9% |
| ៨.៩ ផ្ទីដូង* | Kg | 3,847 | ↓ -10.1% | ↑ 8.7% | ↓ -9.4% |
| ៨.១០ ស្លឹកងប់* | Kg | 5,828 | ↑ 17.8% | ↑ 20.4% | ↑ 12.0% |
| ៨.១១ ត្រយូងល្ពៅ* | Kg | 4,215 | → -4.3% | ↑ 7.2% | → 0.8% |
| ៨.១២ ផ្លែល្ពៅ* | Kg | 2,568 | ↑ 8.9% | ↑ 18.1% | ↑ 13.2% |
| ៨.១៣ ឃ្លោក* | Kg | 2,288 | → -3.2% | → 2.6% | ↑ 11.2% |
| ៨.១៤ ត្រឡាច | Kg | 2,808 | → -0.5% | ↑ 26.6% | ↑ 11.2% |
| ៨.១៥ ត្រប់វែង | Kg | 3,922 | ↑ 13.4% | ↑ 42.7% | ↑ 31.4% |
| ៨.១៦ ត្រប់ស្រួយ* | Kg | 4,077 | ↑ 15.7% | ↑ 58.0% | ↑ 15.4% |
| ៨.១៧ ប៉េងប៉ោះ* | Kg | 3,629 | → -4.2% | ↓ -18.4% | ↓ -35.8% |
| ៨.១៨ ននោងមូល | Kg | 2,860 | ↓ -5.9% | → 4.9% | ↑ 15.6% |
| ៨.១៩ ននោងជ្រុង* | Kg | 3,090 | → 0.7% | ↑ 8.7% | ↑ 13.4% |
| ៨.២០ ល្ពុងខ្វី* | Kg | 1,139 | → 0.8% | ↑ 5.9% | ↑ 8.2% |
| ៨.២១ សណ្តែកគួរ | Kg | 4,616 | ↑ 9.1% | ↑ 44.1% | ↑ 5.9% |
| ៨.២២ ត្រយូងចេក* | Kg | 1,784 | → -3.9% | → 3.2% | ↓ -8.6% |
| ៨.២៣ ផ្កាខាត់ណា* | Kg | 6,500 | ↓ -10.5% | ↓ -20.2% | ↓ -17.0% |
| ៨.២៤ ដើមខាត់ណា* | Kg | 5,661 | → 3.0% | → 3.5% | ↓ -10.5% |
| ៨.២៥ ដំឡូងពណ៌លឿង* | Kg | 2,032 | ↑ 7.1% | → -1.1% | ↑ 14.1% |
| ៨.២៦ ខ្ទឹមសរ | Kg | 4,400 | → -2.9% | ↓ -7.9% | ● |
| ៨.២៧ អំពិលទុំ | Kg | 3,534 | ↓ -6.1% | ↓ -7.1% | ● |
| ៩.១ ចេកណាំវ៉ាទុំ | Kg | 1,751 | → 4.5% | → 3.0% | ● |
| ៩.២ ស្វាយកែវរមៀតទុំ | Kg | 0 | ● | ● | ● |
| ១០.១ ទឹកដោះគោស្រស់ | 140 ml | 1,399 | ↓ -9.6% | ↓ -11.1% | ● |
| ១១.១ កូកាកូឡា | 330 ml | 1,595 | → -1.7% | → -1.6% | ● |
| ៧.១ សាំងធម្មតា | litre | 4,131 | → -3.4% | ↓ -8.5% | ● |
| ៧.២ ម៉ាស៊ូត | litre | 4,546 | ↓ -8.1% | ↓ -10.5% | ● |
| ៨.១ ជី៖ អ៊ុយរ៉េ | Kg | 3,189 | → -3.4% | → -2.3% | ● |

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍គឺជាតម្លៃជាក់ស្តែង ឧ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

** តម្លៃនៃស្បៀងអាហារទាំងនេះ ត្រូវបានប្រមូលពីផ្សារក្នុងខេត្តដែលអនុវត្តកម្មវិធីផ្តល់អាហារលេតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍។*

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

- ↑ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%
- → ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%
- ↓ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%
- ● គ្មានតម្លៃកត់ត្រា

# ឧបសម្ព័ន្ធទី៣៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

ការគណនាតម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ដែលបង្ហាញនៅក្នុងរបាយការណ៍នេះ ផ្អែកចម្បងលើការវិភាគកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា។ ដើម្បីរៀបចំកញ្ចប់អាហារសម្រាប់ការវិភាគនេះ ក្រុមគ្រួសារគោលត្រូវបានវិភាគចេញពីទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៨ ផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

i. គ្រួសារដែលមានការចំណាយប្រចាំខែនៅចន្លោះបញ្ចភាគទី២ និងទី៤
ii. គ្រួសារមានសន្តិសុខស្បៀងគ្រប់គ្រាន់ (ពិន្ទុកម្រិតទទួលទានអាហារអាចទទួលយកបាន)
iii. គ្រួសារមិនបានប្រើប្រាស់យុទ្ធសាស្ត្រអវិជ្ជមានដើម្បីដោះស្រាយបញ្ហាខ្វះស្បៀង។

កញ្ចប់ស្បៀងអាហារសម្រាប់ក្រុមគ្រួសារគោលនេះ ត្រូវបានបង្កើតឡើងដើម្បីស្វែងយល់អំពីទម្រង់នៃការទទួលទានអាហារ ដែលសមស្របទៅនឹងអាហាររបស់គ្រួសារនីមួយៗគួរទទួលទាន ដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម។[1] ដូច្នេះ ស្បៀងអាហារជាក់លាក់ត្រូវបានកំណត់ ដើម្បីជាតំណាងឲ្យក្រុមអាហារនានាដែលមាននៅក្នុងផ្នែកការចំណាយលើស្បៀងអាហារ (សូមមើលតារាងទី២សម្រាប់បញ្ជីស្បៀងអាហារពេញ)។ ថាមពលគីឡូកាឡូរី និងបរិមាណស្បៀងត្រូវបានវិភាគចេញពីទិន្នន័យការចំណាយរបស់អង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៨ ដើម្បីកំណត់កម្រិតកាឡូរីមួយកញ្ចប់សម្រាប់មនុស្សម្នាក់ គួរទទួលទានដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម តាមទម្រង់សិទ្ធិទទួលបានជាមូលដ្ឋាន។

**តារាង២៖ សង្ខេបធាតុចូលសម្រាប់គណនាតម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន**

| ក្រុមអាហារ[2] | ប្រភេទអាហារ[3] | ប្រភេទអាហារ[4] | គីឡូកាឡូរី/ម្នាក់/ថ្ងៃ[2] | ក្រាម/ម្នាក់/ថ្ងៃ[2] | រៀល/ក្រាម[4] | រៀល/ម្នាក់/ខែ[4] |
|---|---|---|---|---|---|---|
| Cereals | Rice | 1.1. អង្ករចម្រុះ/ Mixed Rice | 1,470.23 | 413.0 | 2.1 | 25,817 |
| Fish | Mud fish | 2.1. ត្រីផ្ទក់(រស់)/ Snakehead fish (Live) | 76.47 | 91.0 | 10.7 | 29,487 |
| Meat | Pork | 3.1. សាច់ជ្រូកពពាន់/ 3-layer pork/Pork with fat | 77.75 | 40.7 | 17.1 | 20,458 |
| Egg | Duck egg | 4.1. ស៊ុតទា/Duck egg | 21.92 | 11.8 | 10.1 | 3,268 |
| Diary | Milk | ---NA--- | 7 | 12.0 | - | - |
| Oil | Vegetable oil | 5.1. ប្រេងឆា/ Vegetable Oil: Saji ឬ Mongsay ឬ Cailan | 115.36 | 12.8 | 7.0 | 2,685 |
| Veg | Morning Glory | 8.1. ត្រកួន/ Morning glory | 34.76 | 231.7 | 3.8 | 25,680 |
| Tuber | Sweet Potato | 8.25. ដំឡូងផ្កាពណ៌លឿង/ Orange-flesh Sweet Potatoes | 19.21 | 19.6 | 2.5 | 1,507 |
| Pulses | Soybean/green bean | ---NA--- | 8 | 21.6 | - | - |
| Fruit | Banana | ---NA--- | 91 | 96.4 | - | - |
| | | **Total** | **1,937** | **950.6** | - | **108,901** |

ប្រភេទស្បៀងអាហារមួយចំនួនមិនត្រូវបានតាមដានដោយប្រព័ន្ធតាមដានទីផ្សាររបស់ WFP ដូច្នេះប្រភេទស្បៀងអាហារជាក់លាក់នោះមិនត្រូវបានរាប់បញ្ចូលនៅក្នុងកញ្ចប់ស្បៀងអាហារ ដែលបានតាមដាននៅក្នុងរបាយការណ៍នេះទេ។ ទោះជាយ៉ាងណា ទម្រង់នៃការបរិភោគស្បៀងអាហារនីមួយៗ (ទម្ងន់ គិតជា ក្រាម/ម្នាក់/ថ្ងៃ) អាចតំណាងឲ្យតម្លៃនៃម្ហូបអាហារប្រកបដោយអាហារូបត្ថម្ភ នៅក្នុងប្រទេសកម្ពុជា។

*[1] តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាននៅក្នុងរបាយការណ៍បច្ចុប្បន្នភាពទីផ្សារនេះ មិនដូចគ្នា ជាមួយតម្លៃនៃកញ្ចប់ស្បៀងអាហាររបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការប្រើសម្រាប់គណនាបន្ទាត់ភាពក្រីក្រថ្នាក់ជាតិឡើង។ កញ្ចប់ស្បៀងអាហារនៅក្នុងរបាយការណ៍នេះត្រូវបានគណនាដោយប្រើវិធីសាស្ត្រផ្សេង ហើយមានប្រយោជន៍ជាចម្បងសម្រាប់តម្លៃស្បៀងអាហារ។*
*[2] ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៨ វិទ្យាស្ថានជាតិស្ថិតិ ប្រទេសកម្ពុជា។*
*[3] ការប៉ាន់ប្រមាណពីគម្លាតនៃការចំណាយ និងកញ្ចប់ចំណាយអប្បបរមានៅកម្ពុជា។ របាយការណ៍បច្ចេកទេស ខែមិថុនាឆ្នាំ២០២០ WFP ប្រចាំប្រទេសកម្ពុជា។*
*[4] បច្ចុប្បន្នភាពទីផ្សារ ខែវិច្ឆិកា ឆ្នាំ២០២២ WFP ប្រចាំប្រទេសកម្ពុជា។*